# វគ្គបណ្តុះបណ្តាលគ្រូបង្គោល
# ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម
## សន្ទរកថាបើក
## ឯកឧត្តម ទី ច័ន្ទ្រផល

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ប្រធានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

ថ្ងៃទី០៦-០៨ ខែមេសា ឆ្នាំ២០១៦ - នៅខេត្តបាត់ដំបង

**ឯកឧត្តម លោកជំទាវ គណៈអធិបតី**

**អស់លោក លោកស្រី អង្គពិធីទាំងមូល ជាទីមេត្រី**

ក្នុងនាម **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំ ខ្ញុំមានបិតិសោមនស្សរីករាយ និងមានកិត្តិយសបានមកចូលរួមថ្លែងសន្ទរកថាបើក ក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដែលបានរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងគោលបំណងបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដល់សិក្ខាកាមដែលជាគ្រូបង្គោល ដើម្បីយកទៅធ្វើការបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធមកពី១៤ ខេត្ត និង ៥៤ស្រុកគោលដៅទាំងអស់ដែលនឹងត្រូវអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងឆ្នាំ ២០១៦នេះ។

ឆ្នាំ២០១៦នេះ ជាឆ្នាំទី៣នៃការអនុវត្តន៍កម្មវិធីកំណែទម្រង់ជាអាទិភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ អនុញ្ញាតិឲ្យខ្ញុំបញ្ជាក់ជាសារបានសង្ខេបពីឆន្ទៈរបស់រាជរដ្ឋាភិបាល ជាយុទ្ធសាស្ត្រ ជាគោលនយោបាយ ជាសកម្មភាពអាទិភាព ក្នុងការជម្រុញការងារកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។

### យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣-២០១៨) ដើម្បី **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** បានដាក់ចេញនូវ **គោលដៅយុទ្ធសាស្ត្រ ៤** និង **វិស័យអាទិភាព៤** ដើម្បីឆ្លុះបញ្ចាំងពីប្តេជ្ញាចិត្តក្នុងការអនុវត្ត រយៈពេល៥ឆ្នាំទៅមុខ។ **គោលដៅទី៤- គឺបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។** គោលនយោបាយ កម្មវិធីជាតិ និងសកម្មភាពជាច្រើនបានអនុវត្តពង្រឹង និងពង្រីក ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច **ដើម្បី កំណើន និងការងារ** ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម **ដើម្បី សមធម៌** និង ពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យ **ដើម្បីប្រសិទ្ធភាព។**

**គោលបំណងដ៏ទូលំទូលាយរបស់រដ្ឋាភិបាល** សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ គឺដើម្បីបង្កើតវប្បធម៌ប្រជាធិតេយ្យ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ ការចូលរួមនេះមិនត្រឹមតែចូលរួមក្នុងពេលបោះឆ្នោតជ្រើសតាំងតំណាងរបស់រយៈពេល៥ឆ្នាំម្តងប៉ុណ្ណោះទេ ប៉ុន្តែដំណើរការចូលរួមនេះ ត្រូវធ្វើជាប្រចាំក្នុងគ្រប់ទិដ្ឋភាពនៃអភិបាលកិច្ចនៅមូលដ្ឋាន និងការចូលរួមចំណែកថែរក្សាការពារភូមិ-ឃុំ ឲ្យមានសុវត្ថិភាព ការពារទប់ស្កាត់ចរាចរនិងការប្រើប្រាស់គ្រឿងញៀន ចលនាការពារទប់ស្កាត់គ្រោះថ្នាក់ចរាចរ និងគ្រោះថ្នាក់ដោយសារគ្រោះមហន្តរាយធម្មជាតិ មានព្យុះសង្ឃរា ឬគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួតជាដើម ដែលពាក់ព័ន្ធនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍មូលដ្ឋាន តាមការកែលម្អយន្តការ **ផ្តល់សេវាសាធារណៈ** និងហេដ្ឋារចនាសម្ព័ន្ធដែលនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការចូលរួមកាត់បន្ថយភាពក្រីក្រ។ ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាសិទ្ធិ ជាកាតព្វកិច្ច ជាករណីកិច្ច ជាទុនសង្គមដ៏សំខាន់មិនអាចខ្វះបាន និងជាកត្តាលិករកំណត់ក្នុងការពង្រឹងអភិបាលកិច្ចល្អគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជាដើម្បីឈានទៅសម្រេចការអភិវឌ្ឍន៍ សង្គមសេដ្ឋកិច្ចជាតិ ឱ្យកាន់តែរីកចម្រើនលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាប្រកបដោយសមធម៌និងមាននិរន្តរភាព។

ការតាំងចិត្តរបស់រាជរដ្ឋាភិបាលចំពោះការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក៏មានចែងនៅក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយបានកំណត់យ៉ាងច្បាស់អំពីការតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈ (១)ភាពជាតំណាងសាធារណៈ (២)ស្វ័យភាពរបស់មូលដ្ឋាន (៣)ការពិគ្រោះយោបល់និងការចូលរួម **(៤)ការឆ្លើយតប និងគណនេយ្យភាព** (៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦)ការលើកស្ទួយសមធម៌ (៧)តម្លាភាពនិងសុចរិតភាព និង(៨)វិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច[1] ។

**គោលដៅសំខាន់នៃកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** គឺ ការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ( ទាំងសម្លេង ទាំងសិទ្ធិ និងជីវភាពរស់នៅ) ការលើកកម្ពស់សមភាពរវាងប្រជាពលរដ្ឋក្នុងសហគមន៍ និងការធានានូវយុត្តិធម៌ក្នុងការទទួលបានសេវាសាធារណៈ។ ការកែលម្អ និងការផ្លាស់ប្តូរវិធីយោបទនៃភាពជាតំណាង ព្រមទាំងការផ្តល់ឱកាសចូលរួមជាសម្លេង ជាសិទ្ធដល់ប្រជាពលរដ្ឋកាន់តែទូលំទូលាយ ក្នុងការប្រាស្រ័យទាក់ទងជាមួយតំណាងរបស់ខ្លួន និងការជម្រុញឱ្យមានគណនេយ្យភាព កាន់តែខ្លាំងឡើងរបស់ក្រុមប្រឹក្សា និងមន្ត្រីនានាចំពោះប្រជាពលរដ្ឋ នឹងបង្កើននូវ **មូលធនសង្គម** និងការផ្សារភ្ជាប់គ្នានៅសហគមន៍ គឺជាធាតុចូលដ៏មានសារសំខាន់ និងមាន **ប្រសិទ្ធភាព**ក្នុងដំណើរការអភិវឌ្ឍន៍សង្គមជាតិ ឱ្យបានរុងរឿងគ្រប់វិស័យ គ្រប់ជ្រុងជ្រោយទៅអនាគត។ **ប្រសិទ្ធភាព** កើតមកពីសុចរិតភាព តម្លាភាព គណនេយ្យភាព តាមគោលការពង្រឹងនិតិរដ្ឋ លទ្ធិប្រជា

[1] NP-SNDD, 2010-2019, page 16

ធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម និងការបង្ករគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងកត្តារួមផ្សំជាច្រើនទៀត។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពនេះចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ព្រមទាំងមន្ត្រី បុគ្គលិកដែលជាអ្នកប្រតិបត្តិការផ្ទាល់។ មន្ត្រី បុគ្គលិក និងរដ្ឋបាលរបស់ខ្លួន ត្រូវមានការផ្លាស់ប្តូរ និងប្រែក្លាយខ្លួនឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព សំដៅបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងស្របតាមការរីកចម្រើនរបស់សង្គម។ ក្នុងន័យនេះ មន្ត្រី បុគ្គលិក និងរដ្ឋបាលរបស់ខ្លួន ត្រូវបំពេញការងារប្រកបដោយឆន្ទៈមោះមុត មានកក្តីភាពចំពោះរដ្ឋ និងប្រជាពលរដ្ឋ ព្រមទាំងមានសីលធម៌វិជ្ជាជីវៈខ្ពស់បំផុតដើម្បីបំពេញការងាររបស់ខ្លួនប្រកបដោយតម្លាភាព សមត្ថភាព និងប្រសិទ្ធភាព។

**ការលើកកំពស់គុណភាពនៃការផ្តល់សេវារដ្ឋបាល** គឺជាយុទ្ធសាស្ត្រដ៏មានសារៈសំខាន់បំផុត ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជារដ្ឋបាលមានសក្តានុពល និងមានសមត្ថភាពខ្ពស់ជាងមុនក្នុងការផ្តល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ និងបង្កលក្ខណៈងាយស្រួលដល់អ្នកស្នើសុំ និងអ្នកប្រើប្រាស់សេវា ព្រមទាំងពង្រឹងនូវយន្តការទទួលព័ត៌មាន និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។ ទាំងនេះ គឺជាយុទ្ធសាស្ត្រអាទិភាពដ៏សំខាន់នៅក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។

សូចនាករគោលសំខាន់ៗចំនួន៥ នឹងត្រូវបានកំណត់ឡើង សម្រាប់ធ្វើការវាស់ស្ទង់អំពីគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក្នុងនោះរួមមាន៖ **ទី១**.គុណភាពព័ត៌មាន **ទី២**.ភាពងាយស្រួលក្នុងការទទួលយកសេវា **ទី៣**.ការយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា **ទី៤**.សេវាផ្តល់តាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ និង**ទី៥**.យន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។

## ផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ ឬហៅថា "ផអ៣ទី២"

ផ្អែកលើមូលដ្ឋាននៃសមិទ្ធផល បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តក្នុងដំណាក់កាលដំបូងនេះ ផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ សម្រាប់ការអនុវត្តពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ នៃកម្មវិធីជាតិ ឬហៅថា "ផអ៣ទី២" ក៏ត្រូវបានរៀបចំតាក់តែងឡើងដោយមានការសិក្សា ការពិភាក្សា និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយបណ្តាក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ព្រមទាំងត្រូវបានពិនិត្យអនុម័ត ដោយកិច្ចប្រជុំលើកទី១០របស់ គ.ជ.អ.ប. នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ កន្លងទៅថ្មីៗនេះ។

**ផអ៣ទី២** គឺជាផែនការអនុវត្តរយៈពេលមធ្យមដ៏មានសារៈសំខាន់មួយសម្រាប់បន្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងបេត់ផ្លូវមួយដែលតម្រូវឲ្យមានការតាំងចិត្តយ៉ាងមោះមុត ក្នុង

ការអនុវត្តកំណែទម្រង់នេះឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ស្របតាមស្មារតីនៃច្បាប់អង្គការ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥។

ឯកសារផអ៣ទី២ (២០១៥-២០១៧) បានកំណត់គណនេយ្យភាពចំនួន៣ប្រភេទ ដែលនឹងត្រូវពង្រឹងបន្ថែមទៀត ក្នុងនោះរួមមាន ៖

**ប្រភេទទី១ ៖ គណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សារបស់ខ្លួន** នឹងត្រូវបានពង្រឹងតាមរយៈការកែលម្អ និងការលើកកម្ពស់ការអនុវត្តនូវក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា ការសម្របសម្រួលឱ្យក្រុង ស្រុកនីមួយៗ ធ្វើការរៀបចំ និងអនុម័តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន និងការរៀបចំឱ្យមានប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងតាមបច្ចេកវិទ្យាព័ត៌មាន ដើម្បីជានាផ្តល់នូវព័ត៌មានគ្រប់គ្រាន់ដល់ក្រុមប្រឹក្សាក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។

ការអនុវត្តសកម្មភាពទាំងនេះ នឹងបង្កើននូវគណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សារបស់ខ្លួន ហើយការបំពេញការងាររបស់ក្រុមប្រឹក្សាមានលក្ខណៈកាន់តែល្អប្រសើរឡើងក្នុងការកំណត់ទិសដៅ ជាយុទ្ធសាស្ត្ររបស់ខ្លួន ព្រមទាំងមានព័ត៌មានគ្រប់គ្រាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនានា។ ទាក់ទង នឹងគណនេយ្យភាពប្រភេទទី១នេះ អង្គភាព ត្រួតពិនិត្យនិងវាយតម្លៃ នៃលេខាធិការដ្ឋានគ.ជ.អ.ប នឹងជួយគាំទ្ររៀបចំជាប្រព័ន្ធMISមួយ នៅក្នុងឆ្នាំ ២០១៥ និងដាក់ឱ្យសាកល្បង នៅក្រុងស្រុកចំនួន១០ មុននឹងដាក់ឱ្យអនុវត្តពេលលេញនៅឆ្នាំបន្ទាប់។

**ប្រភេទទី២ ៖ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋរបស់ខ្លួន** នឹងត្រូវបានលើកកម្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា តាមរយៈការរៀបចំ និងការអនុវត្តសកម្មភាពនានានៃការងារគណនេយ្យភាពសង្គម យន្តការដោះស្រាយបណ្តឹង និងការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអនុវត្តសកម្មភាពទាំងនេះនឹងបង្កើនឡើងនូវការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយប្រជាពលរដ្ឋនឹងកាន់តែទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ដើម្បីចូលរួមត្រួតពិនិត្យនិងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអាចមានលទ្ធភាពចូលរួមផ្តល់យោបល់កែលម្អដល់ការបំពេញការងាររដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ប្រភេទទី៣ ៖ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល** នឹងត្រូវពង្រឹងតាមរយៈការរៀបចំ និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធអធិការកិច្ចក្នុងគោលបំណងលើកកម្ពស់កិច្ចប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារនានាដែលបានកំណត់។

## ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

**គណនេយ្យភាពសង្គម** គឺជាផ្នែកមួយនៃការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យនៅកម្ពុជា **គឺជាឧបករណ៍ដ៏មានសារៈសំខាន់ ក្នុងការចូលរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន** ដោយឈរលើគោលការណ៍មូលដ្ឋាន គឺ-(១) ការទទួលបានព័ត៌មាន -(២) ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និង-(៣)ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋក្នុងដំណើរការពិភាក្សាចរចារធ្វើឲ្យមានភាពប្រសើរឡើង។

ការកែលម្អ និងការផ្លាស់ប្តូរវិយាបទនៃភាពជាតំណាង ព្រមទាំងការផ្តល់ឱកាសចូលរួមជាសម្លេងជាសិទ្ធិដល់ប្រជាពលរដ្ឋកាន់តែទូលំទូលាយ ក្នុងការប្រាស្រ័យទាក់ទងជាមួយតំណាងរបស់ខ្លួន និងការជម្រុញឱ្យមានគណនេយ្យភាពកាន់តែខ្លាំងឡើងរបស់ក្រុមប្រឹក្សានិងមន្ត្រីនានាចំពោះប្រជាពលរដ្ឋនឹងបង្កើននូវ **មូលធនសង្គម** និងការផ្សារភ្ជាប់នៅសហគមន៍ គឺជាធាតុចូលដ៏មានសារសំខាន់ និងមាន **ប្រសិទ្ធភាព** ក្នុងដំណើរការការអភិវឌ្ឍន៍សង្គមជាតិឱ្យបានរុងរឿងគ្រប់វិស័យទៅអនាគត។

ទាក់ទងនិងគណនេយ្យភាពសង្គម **គ.ជ.អ.ប** បានរៀបចំនិងអនុម័ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ បន្ទាប់មកបានរៀបចំសេចក្តីព្រាងផែនការអនុវត្ត៣ឆ្នាំ ដើម្បីប្រែក្លាយយុទ្ធសាស្ត្រនោះឱ្យទៅជាសកម្មភាពជាក់ស្តែង ដែលយើងបានសាកល្បងនៅក្នុងស្រុកចំនួន២២ ក្នុងឆ្នាំ២០១៤ កន្លងមក ជាមួយអង្គការសង្គមស៊ីវិលជាដៃគូចំនួន៦[2]។ កន្លងមក លេខាធិការដ្ឋានគ.ជ.អ.ប បានរៀបចំជាផ្ទាំងរូបភាពព័ត៌មានស្តីពីការផ្តល់សេវារបស់សាលាឃុំ សាលាបឋមសិក្សា និង មណ្ឌលសុខភាព ដែលមានបញ្ចូលព័ត៌មានអំពីស្តង់ដារសេវាកម្ម ព័ត៌មានអំពីសិទ្ធិប្រជាពលរដ្ឋ និងព័ត៌មានអំពីថវិកា និងការប្រើប្រាស់ថវិកា ដើម្បីយកទៅផ្សព្វផ្សាយជាសាធារណៈនៅគ្រប់ឃុំ[3] ក្នុងស្រុកចំនួន២២នៃខេត្តចំនួន១២ ដែលគ្របដណ្តប់ប្រជាពលរដ្ឋសរុបប្រមាណ១,៥លាននាក់។ ចំណែកអង្គការដៃគូវិញ បានខិតខំអនុវត្តដំណើរការត្រួតពិនិត្យវាយតម្លៃ ដោយប្រជាពលរដ្ឋ ដោយរៀបចំបានប័ណ្ណដាក់ពិន្ទុ ទៅលើសេវាកម្មរបស់សាលាឃុំ សាលារៀន និងមណ្ឌលសុខភាព ដែលមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកផ្តល់សេវានៅមូលដ្ឋានផងដែរ ផែនការសកម្មភាពគណនេយ្យភាពរួម សម្រាប់កែលម្អសេវាកម្មទាំងនោះ ហើយនិងបានបង្កើត គណៈកម្មការ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពគណនេយ្យភាពរួមផងដែរ។

## ផែនការអនុវត្ត៣ឆ្នាំ២០១៦-២០១៨

នៅខែកក្កដា ឆ្នាំ២០១៣ គ.ជ.អ.ប បានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានគូសបញ្ជាក់អំពីចក្ខុវិស័យ គោលបំណង លទ្ធផលរំពឹងទុក និងគោលការណ៍គន្លឹះនានាសម្រាប់គណនេយ្យភាពសង្គម ព្រមទាំងយុទ្ធសាស្ត្រគន្លឹះចំនួនប្រាំដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋធ្វើការងាររួមគ្នាក្នុងការអភិវឌ្ឍនៅមូលដ្ឋាន។

[2] PACT, WVI, RACHA, Save the Children, CARE and STAR Kampuchea

[3] សាលាឃុំចំនួន186ឃុំ សាលាបឋមសិក្សាចំនួន 891សាលា មណ្ឌលសុខភាពចំនួន136 មណ្ឌល។

បន្ទាប់ពីបានអនុម័តឯកសារផែនការយុទ្ធសាស្ត្ររួចមក គ.ជ.អ.បបានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិដើម្បីរៀបចំជាឯកសារផែនការអនុវត្តគណនេយ្យភាពសង្គមឡើងសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៨ ដែលឯកសារនេះបានអនុម័តជាគោលការណ៍ក្នុងកិច្ចប្រជុំលើកទី២របស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមបានព្រមទាំងបានអនុម័តនូវក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គមដោយកំណត់យកឆ្នាំ២០១៦ ចំនួន ៥៤ស្រុក ឆ្នាំ២០១៧ចំនួន៤៦ ស្រុកបន្ថែមទៀត (សរុប១០០ស្រុក) និងឆ្នាំ២០១៨ ចំនួន២០ ស្រុកបន្ថែមទៀត (សរុប១២០ស្រុក)។ សម្រាប់ត្រឹមាសទី១ ឆ្នាំ២០១៦នេះ ដោយទទួលបានការគាំទ្របច្ចេកទេសពី UNICEF លេខាធិការដ្ឋានគ.ជ.អ.ប បានរៀបចំរួចរាល់នូវប្រព័ន្ធប្រមូល និងបញ្ចូលទិន្នន័យ online សម្រាប់ស្រុក និងបញ្ចូលឲ្យអនុវត្តផ្ទាល់ក្នុងវគ្គបណ្តុះបណ្តាលនេះ ព្រមទាំងដាក់ឲ្យប្រើប្រាស់ជាផ្លូវការបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ។

ម្យ៉ាងទៀតវគ្គផ្សព្វផ្សាយអំពីការងារគណនេយ្យភាពសង្គមត្រូវបានរៀបចំនៅថ្នាក់ខេត្ត និងស្រុកគោលដៅ ដើម្បីឲ្យការបិទផ្សាយព័ត៌មាននៅគ្រប់ឃុំ គ្រប់មណ្ឌលសុខភាព និងគ្រប់សាលាបឋមសិក្សា រួចរាល់នៅបំណាច់ខែមេសានេះ។ ក្នុងការអនុវត្តឆ្នាំ២០១៦ លេខាធិការដ្ឋានគ.ជ.អ.ប នឹងសហការជាមួយអង្គការដៃគូអនុវត្តចំនួន៥ ដែលមាន៖

១-អង្គការ CARE(១០ស្រុក) : ខេត្តកោះកុង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តកំពត
២-អង្គការ Save the Children(១០ស្រុក): ខេត្តព្រៃវែង-ពោធិ៍សាត់ -ត្បូងឃ្មុំ និងខេត្តក្រចេះ
៣-អង្គការ RACHA(២១ស្រុក): ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន
៤-អង្គការ World Vision(១១ស្រុក): ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តសៀមរាប
៥-អង្គការ Star Kampuchea(២ស្រុក): ខេត្តស្វាយរៀង

## ចំណុចសំខាន់ៗសម្រាប់ការណែនាំបន្ថែមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល

ខ្ញុំសង្ឃឹមថាវគ្គបណ្តុះបណ្តាលនេះ នឹងអាចផ្តល់ចំណេះដឹង ពុទ្ធិថ្មីៗថែមទៀត សម្រាប់យកទៅកែលម្អ ធ្វើការបណ្តុះបណ្តាលបន្ត ការអនុវត្តជាក់ស្តែងនៅស្រុកទាំង៥៤ និងបន្តពង្រីកទៅស្រុកផ្សេងៗទៀតតាមការចាំបាច់។ ខ្ញុំយល់ថានៅពេលដែលមុខងារជាច្រើន បានប្រគល់ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នោះដំណើរការគណនេយ្យភាពសង្គម ពោលគឺប្រព័ន្ធត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (**Citizen Motoring**) នឹងក្លាយជាដំណើរការដ៏មានសារៈសំខាន់ចាំបាច់ **ជាកញ្ចក់ឆ្លុះបញ្ចាំង** អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តមុខងារទាំងនោះទៅថ្ងៃអនាគត ព្រមទាំង **អាចជាសារ** ផ្តល់ជូនអ្នករៀបចំគោលនយោបាយ នៅថ្នាក់មូលដ្ឋាន (ក្រុមប្រឹក្សា ក្រុងស្រុក និងរាជធានី ខេត្ត) និងថ្នាក់ជាតិ ឱ្យបានដឹងអំពីការវិឌ្ឍន៍ផ្លាស់ប្តូរនៃអភិបាលកិច្ចមូលដ្ឋាន ដែលជាផលបានមកពីនយោបាយកំណែទម្រង់ជាតិរបស់យើង។ ក្នុងន័យនេះ អ្នករៀបចំគោលនយោបាយ អាចពិចារណា រៀបចំគោលនយោបាយមួយ ដែលមានលក្ខណៈឆ្លើយតប ទៅនិងតម្រូវការជាក់ស្តែង របស់ប្រជាពលរដ្ឋបានកាន់តែល្អប្រសើរឡើង។ អាស្រ័យហេតុនេះ ដំណើរការ

គណនេយ្យភាពសង្គម និង ត្រូវពង្រីកបន្ថែម ទៅលើវិស័យផ្សេងទៀត ក្រៅពីវិស័យជាមូលដ្ឋានទាំង៣ ដែលយើងបាននិងកំពុងអនុវត្ត ពេលបច្ចុប្បន្ន។

- **ការពង្រឹងភាពជាដៃគូ៖**

ដូចដែលមានចែងក្នុងចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមគឺការអនុវត្តការងារគណនេយ្យភាពសង្គមត្រូវផ្តោតលើ**ការពង្រឹងភាពជាដៃគូ** រវាងរដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (I-SAF Partnership Steering Committee) បានបង្កើតឡើង ដោយមានសមាភាព៦ រូបពីផ្នែកផ្គត់ផ្គង់ និង៦រូប ពីផ្នែកតម្រូវការ (អង្គការសង្គមស៊ីវិល) ព្រមទាំងអ្នកអង្កេតការ២រូប មកពីតំណាងដៃគូអភិវឌ្ឍ។ គណកម្មាធិការបានប្រជុំចំនួន ២លើករួចមកហើយ ដោយជាលទ្ធផលគឺបានអនុម័តជាគោលការណ៍លើ -១)តំបន់គោលដៅក្នុងការអនុវត្តឆ្នាំ ២០១៦ -២) អនុស្សារណៈយោគយល់គ្នារវាង គ.ជ.អ.ប និងអង្គការសង្គមស៊ីវិលទាំងប្រាំ និង ៣) សេចក្តីព្រាងផែនការអនុវត្តរយៈពេលបីឆ្នាំ។

ដូចនេះសូមឲ្យបន្តយន្តការនៃការសហការល្អក្នុងភាពជាដៃគូ នៅថ្នាក់ក្រោមជាតិ រួមទាំងសកម្មភាពនៃការកសាងសមត្ថភាព (ដូចជាវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា) ដែលអនុវត្តដោយទាំងពីរផ្នែក (ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) និងការអនុវត្តសកម្មភាពនានាជាក់ស្តែងនៅមូលដ្ឋាន ។

- **ជំរុញការអនុវត្តការបិទផ្សាយព័ត៌មាន៖**

សូមឲ្យខេត្ត និងស្រុក (ពិសេសមន្ត្រីបង្គោលគណនេយ្យភាពសង្គមខេត្ត និងស្រុក) ជំរុញ និងគាំទ្រធ្វើយ៉ាងណាឲ្យគ្រប់ឃុំ គ្រប់មណ្ឌលសុខភាព និងគ្រប់សាលាបឋមសិក្សាអាចបិទផ្សាយព័ត៌មាន (ទាំងព័ត៌មានសិទ្ធ ស្តង់ដា ការបំពេញការងារ និងថវិកា)បានទាន់ពេលវេលា ស្របតាម**វដ្ត**នៃការអនុវត្តផែនការគណនេយ្យភាពសង្គម (ខែមករា-មេសា)។

- **ជំរុញការអនុវត្តប័ណ្ណដាក់ពិន្ទុអនុវត្តស្របតាមនិតិវិធី និងទាន់ពេលវេលា៖**

សូមឲ្យអង្គការសង្គមស៊ីវិលទាំងអស់ដែលបានចុះអនុស្សារណៈយោគយល់គ្នា ពន្លឿនការអនុវត្ត និងអនុវត្តឲ្យទាន់ពេលវេលា (ឧទាហរណ៍ជាក់ស្តែងគិតត្រឹមខែមីនា ឆ្នាំ២០១៦ អង្គការ CARE នៅមិនទាន់ជ្រើសរើសអង្គការដៃគូអនុវត្តនៅមូលដ្ឋាននៅឡើយ)។

សូមឲ្យអង្គការសង្គមស៊ីវិលទាំងអស់ជួយជំរុញ ធ្វើយ៉ាងណាឲ្យការរៀបចំការដាក់ពិន្ទុ៖

- ផ្អែកតាមព័ត៌មានដែលបានបិទផ្សាយ (ជាបទពិសោធន៍កន្លងមក កាលណាការបំផុសសំនួរទៅប្រជាពលរដ្ឋ ដោយមិនមានផ្អែកលើព័ត៌មាននៅលើកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4C) ដែលបានបិទផ្សាយ ធ្វើឲ្យលទ្ធផលនៃបញ្ហា ឬសកម្មភាព ចេញពីការដាក់ពិន្ទុ ហាក់ទូលំទូលាយពេក និងពុំឆ្លើយនឹងលក្ខណៈវិនិច្ឆ័យ និងក្រៅវង្វង់ព័ត៌មានដែលបានបិទផ្សាយ)
- ការសម្របសម្រួលការដាក់ពិន្ទុដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) ត្រូវមានភាពសុក្រិត អព្យាក្រិត និងសម្របសម្រួលដោយមិនមានភាពលំអៀងនិង ត្រូវគោរពតាមគោលការណ៍ទាំង៧របស់យុទ្ធសាស្ត្រគណនេយ្យភាពសង្គម

▪ **ការសហការគាំទ្រពីមន្ទីរជំនាញ៖**

ដូចឯកឧត្តម លោកជំទាវ អស់លោក លោកស្រីបានជ្រាបស្រាប់ហើយប្រត្តិបត្តិករ ដែល អនុវត្ត ផ្ទាល់គឺរដ្ឋបាលថ្នាក់ស្រុក ការិយាល័យអប់រំ យុវជន និងកីឡា និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា តែទោះបីជាយ៉ាងណាក៏ដោយ ការសហការគាំទ្រពី រដ្ឋបាល និងស្ថាប័នខ្សែបណ្ដោយផ្សេងៗ ដូចរដ្ឋបាលខេត្ត មន្ទីរសុខាភិបាល និងមន្ទីរអប់រំយុវជន និង កីឡាខេត្ត និងស្ថាប័នផ្សេងៗទៀត គឺមិនអាចកាត់ផ្ដាច់បានឡើយ។

▪ **ការត្រួតពិនិត្យតាមដាន៖**

សូមឲ្យមានការត្រួតពិនិត្យ និងតាមដានជាប្រចាំក្នុងការអនុវត្តយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដើម្បីធានាថាការអនុវត្តនេះប្រព្រឹត្តទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានា ដែលបានដាក់ចេញ និងរៀនសូត្រពីការអនុវត្ត ដើម្បីកែលម្អក្នុងការអនុវត្តជាបន្តបន្ទាប់ទៀត ។

ចុងក្រោយនេះ និងក៏ជាអនុសាសន៍**សម្ដេចតេជោនាយករដ្ឋមន្ត្រី** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ដែល **សម្ដេច** តែងតែលើកឡើងក្នុងកិច្ចប្រជុំ និងសិក្ខាសាលាជាច្រើនកន្លងមកផងដែរ ក្នុងនាមជាមន្ត្រី រាជការ និងអ្នកផ្ដល់សេវាដល់ប្រជាពលរដ្ឋត្រូវប្រកាន់នូវអាកប្បកិរិយា និងគោលការណ៍ថាខ្លួនគឺជាអ្នកបំរើ រាស្ត្រ មិនមែនចៅហ្វាយរាស្ត្រនោះទេ។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល នានា ដែលបានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយបានផ្ដល់នូវការ គាំទ្រទាំង ផ្នែកហិរញ្ញប្បទាន និងជំនួយបច្ចេកទេសជាច្រើន ក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាននៅកម្ពុជាកន្លង មក។ ទន្ទឹមនេះ ខ្ញុំសូមស្នើ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ផ្ដល់ការគាំទ្រនិងចូលរួមអនុវត្ត ផែនការអនុវត្ត គណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីសម្រេចឱ្យបាន ជោគជ័យត្រចះត្រចង់តាមការរំពឹងទុក។

ក្នុងឱកាស បុណ្យចូលឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ព.ស២៥៦០ ដែលនឹងឈានមកដល់ ក្នុងរយៈពេល៦ថ្ងៃទៀតនេះ ខ្ញុំ សូមប្រសិទ្ធពរជ័យសេរីមង្គលវិបុលសុខជូនដល់ឯកឧត្តម លោកជំទាវ លោក ស្រី អស់លោក និងអង្គសិក្ខាសាលាទាំងអស់ សូមមានសុខភាពល្អ សិរីសួស្ដី ជួបប្រទះតែពុទ្ធពរទាំងបួន ប្រការ គឺ *អាយុ វណ្ណៈ សុខៈ ពលៈ* កុំបីឃ្លៀងឃ្លាត និងសូមប្រកាសបើក វគ្គបណ្ដុះបណ្ដាល គ្រូបង្គោលស្ដីពីការអនុវត្តផែនការគណនេយ្យភាពសង្គមចាប់ពីពេលនេះតទៅ។ **សូមអរគុណ។**